ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៦៣

ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩

សាលដីកា

លេខ ៥៨ "III"

ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០

ដោយអង្គជំនុំជម្រះដែលមានសមាសភាពដូចខាងក្រោម៖

១-ឯកឧត្តម [redacted] ជាប្រធាន

២-លោក [redacted] ជាចៅក្រម

៣-លោក [redacted] ជាចៅក្រម

៤-លោក [redacted] ជាចៅក្រម

៥-លោក [redacted] ជាចៅក្រម

**ក្រឡាបញ្ជីសវនាការ**

កញ្ញា [redacted]

**តំណាងមហាអយ្យការ**

លោក [redacted] ឋានៈជាព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ៣២៧ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ម៉េងឃៀង ដែលប្តឹងសាទុក្ខចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៧០ ក្រIII "ឃ" ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញដែលមាន៖

**បុគ្គលប្តឹងសាទុក្ខ**

-ជនត្រូវចោទឈ្មោះ [redacted] ម៉េងឃៀង ភេទប្រុស អាយុ ៣៤ ឆ្នាំ ជាតិខ្មែរ មុខរបរជាងថតរូប មានទីកន្លែងកំណើត [redacted] ខេត្តកណ្តាល មានទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តកណ្តាល។ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន០៣នាក់។ ទោសពីមុនគ្មាន ។

-លោកមេធាវី [redacted] ដូងី ជាអ្នកការពារ ។



Scanned with CamScanner

ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមពីការពិនិត្យពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ ប្រព្រឹត្តនៅចំណុចភូមិដំរីឆ្លង ឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបទប្បញ្ញត្តិមាត្រា ៤៩៤ និងមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៨ ឈ្មោះ [redacted] ម៉េងឃៀង បានធ្វើសកម្មភាពជួបជុំសកម្មជនអតីតបក្សសង្គ្រោះជាតិចំនួន ២០ នាក់ នៅផ្ទះរបស់ឈ្មោះ [redacted] ស៊ុន ស្ថិតនៅភូមិព្រែកតាសៅ ឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្តាល ដោយបានបង្ហោះរូបភាពនិងបានសរសេរលើបណ្តាញទំនាក់ទំនងសង្គម (Face booK) រួមគ្នាគាំទ្រគំនិតរបស់ទណ្ឌិត [redacted]។ ក្រោយធ្វើសកម្មភាពរួចហើយ សមត្ថកិច្ចបានកោះហៅឈ្មោះ [redacted] ម៉េងឃៀង និងបក្សពួក ឱ្យមកធ្វើកិច្ចសន្យាបញ្ឈប់សកម្មភាពនេះ។ ប៉ុន្តែ បុគ្គលឈ្មោះ [redacted] ម៉េងឃៀង នៅតែបន្តសកម្មភាពដូចជា ការជួបជុំស៊ីនបញ្ចុកសង្គ្រោះជាតិ គាំទ្រ EBA អំពាវនាវឱ្យកងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋមិនឱ្យស្តាប់បង្គាប់អាជ្ញាធរ ឱ្យក្រោកឈរប្រឆាំងនឹងរាជរដ្ឋាភិបាល ។

ថ្មីៗនេះ ក្រុមឧទ្ទាមបានអំពាវនាវឱ្យកងកម្លាំងនិងប្រជាពលរដ្ឋប្រឆាំងនឹងរាជរដ្ឋាភិបាលស្របច្បាប់ និងគាំទ្រទណ្ឌិត សម រង្ស៊ី ចូលប្រទេសកម្ពុជា នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ដើម្បីផ្តួលរំលំរាជរដ្ឋាភិបាល ។

-បានឃើញ ដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នលេខ ២៨៣៩ ដកសយខ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកណ្តាល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

-ឃុំខ្លួនជនត្រូវចោទឈ្មោះ [redacted] ម៉េងឃៀង ជាបណ្តោះអាសន្ន។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ០១៨ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់លោក [redacted] ជូងី ជាមេធាវីតំណាងជនត្រូវចោទឈ្មោះ [redacted] ម៉េងឃៀង ក្នុងការប្តឹងឧទ្ធរណ៍ ដែលប្តឹងមិនសុខចិត្តនឹងដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នលេខ ២៨៣៩ ដកសយខ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

សាលាឧទ្ធរណ៍ភ្នំពេញបានសម្រេចតាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ៧០ ក្រIII "ឃ" ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ០១៨ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់លោក [redacted] ជូងី ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] ម៉េងឃៀង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលេខ ២៨៣៩ ដកសយខ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល ទុកជាបានការដដែល ។

៣-សាលដីកានេះ ប្រកាសជាអសាធារណៈ នៅថ្ងៃព្រហស្បតិ៍ ១២កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ ។

បើកសិទ្ធិឱ្យប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

Scanned with CamScanner

-បានឃើញ បណ្ដឹងសាទុក្ខលេខ ៣២៧ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៩ របស់ជនត្រូវចោទ ឈ្មោះ [redacted] ម៉េងឃៀង ប្ដឹងសាទុក្ខនឹងសាលដីកាព្រហ្មទណ្ឌលេខ ៧០ ក្រIII "ឃ" ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល។

**នាពេលសវនាការ**

-ចៅក្រមរបាយការណ៍អានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលធ្វើសេចក្ដីសន្និដ្ឋាននិងប្ដឹងសុំថា ការសម្រេចសេចក្ដីរបស់សាលាឧទ្ធរណ៍ ដែលបានតម្កល់ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នរបស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាលទុកជាបានការដដែលនោះ គឺមានសំអាងហេតុនិងភស្ដុតាងត្រឹមត្រូវតាមច្បាប់ ។ ប៉ុន្តែពិនិត្យតាមស្ថានភាពជាក់ស្ដែង ជនត្រូវចោទ ត្រូវបានចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាលដោះលែងឱ្យនៅក្រៅឃុំរួចហើយ ។

-ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានពិនិត្យ ពិភាក្សា ពិចារណា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ

**សំអាងហេតុ**

**តុលាការកំពូល**

១-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ៣២៧ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ របស់លោកមេធាវី [redacted] ជូនី ជាអ្នកតំណាងឱ្យជនត្រូវចោទឈ្មោះ [redacted] ម៉េងឃៀង ក្នុងការប្ដឹងសាទុក្ខនឹងសាលដីកាលេខ ៧០ ក្រ III "ឃ" ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន តាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ និងបទប្បញ្ញត្តិមាត្រា ៤១៧ , មាត្រា ៤១៨, មាត្រា ៤២០, និងមាត្រា ៤២២ កថាខណ្ឌ២ វាក្យខណ្ឌ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា សាលដីកាលេខ ៧០ ក្រIII "ឃ" ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញដែលបានសម្រេចតម្កល់ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នលេខ ២៨៣៩ ដកសយខ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាលទុកជាបានការដដែលនោះលែងមានភាពសំខាន់ចាំបាច់តទៅទៀតហើយ ដោយហេតុថា តាមការជាក់ស្ដែង ជនត្រូវចោទក្នុងរឿងក្ដីនេះ ឈ្មោះ [redacted] ម៉េងឃៀង ត្រូវបានចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាលបានសម្រេចដោះលែងឱ្យនៅក្រៅការឃុំខ្លួនរួចហើយ ។

៣-យល់ឃើញថា សេចក្ដីសន្និដ្ឋាននិង កំណត់សម្គាល់របស់តំណាងមហាអយ្យការអមតុលាការកំពូល ថាជនត្រូវចោទ [redacted] ម៉េងឃៀង ត្រូវបានចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាលបានដោះលែងឱ្យនៅ

Scanned with CamScanner

ក្រៅឃុំរួចហើយ ដែលសេចក្ដីសន្និដ្ឋាននេះមានមូលដ្ឋានសមស្រប អាចឱ្យតុលាការកំពូលជឿបាន ។

៤-យល់ឃើញថា ផ្អែកតាមព័ត៌មានគួរឱ្យជឿជាក់បានដូចបានលើកបង្ហាញត្រង់ចំណុចសំអាងហេតុទី ២ និងទី៣ ខាងលើនេះ បណ្ដឹងសាទុក្ខលេខ ៣២៧ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ របស់លោកមេធាវី [redacted] ជូងី ជាអ្នកតំណាងឱ្យជនត្រូវចោទឈ្មោះ [redacted] ម៉េងឃៀង ក្នុងការប្ដឹងសាទុក្ខនឹងសាលដីកាលេខ ៧០ ក្រIII “ឃ” ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញនោះ លែងជាកម្មវត្ថុនៃការវិនិច្ឆ័យរបស់តុលាការកំពូលតទៅទៀតហើយ ។

## ហេតុដូច្នេះ

## សម្រេចសេចក្ដី

ប្រកាសថា មិនវិនិច្ឆ័យលើបណ្ដឹងសាទុក្ខលេខ ៣២៧ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ របស់លោកមេធាវី [redacted] ជូងី ជាអ្នកតំណាងឱ្យជនត្រូវចោទឈ្មោះ លី ម៉េងឃៀង ក្នុងការប្ដឹងសាទុក្ខ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃចន្ទ ទី០២ ខែមីនា ឆ្នាំ២០២០ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃចន្ទ ទី០៩ ខែមីនា ឆ្នាំ២០២០ ។

Scanned with CamScanner